# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ: ១០ . សរព..

# សារលិខិត

**របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**
**ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី១២៨ នៃទិវាពលកម្មអន្តរជាតិ**
**ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៤**

*បងប្អូនកម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា!*

តាងនាមរាជរដ្ឋាភិបាលកម្ពុជា និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំមានក្តីបីតិសោមនស្សរីករាយយ៉ាងក្រៃលែង ក្នុងការចូលរួមអបអរសាទរយ៉ាងស្មោះស្ម័គ្របំផុតជាមួយបងប្អូនកម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ ក្នុងឱកាសប្រារព្ធខួបអនុស្សាវរីយ៍លើកទី១២៨ នៃទិវាពលកម្មអន្តជាតិ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០១៤ នេះ។ ឆ្លៀតឱកាសនេះ ខ្ញុំសូមរំលឹកឡើងវិញដោយសង្ខេបថា ចលនាកម្មករអន្តរជាតិនេះបានកើតឡើងនៅក្នុងប្រទេសមួយចំនួនតាំងពី១២៨ឆ្នាំមុន ក្នុងគោលបំណងទាមទារឱ្យមានការកែលម្អលក្ខខណ្ឌការងារ និងជីវភាពប្រជាពលករ ហើយបានក្លាយជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រអន្តរជាតិជារៀងរហូតមក។

ដោយឡែក នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើង ទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា ត្រូវបានប្រារព្ធឡើងជារៀងរាល់ឆ្នាំ ចាប់តាំងពីប្រទេសត្រូវបានរំដោះពីរបបប្រល័យពូជសាសន៍នាថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ រហូតមកដល់ពេលបច្ចុប្បន្ន ដែលរាជរដ្ឋាភិបាលបានកំណត់យកទិវានេះជាថ្ងៃឈប់សម្រាកផ្លូវការរបស់មន្ត្រីរាជការ និងកម្មករនិយោជិតទាំងអស់។

*បងប្អូនកម្មករនិយោជិត និយោជក និងជនរួមជាតិ ជាទីមេត្រី!*

រាជរដ្ឋាភិបាលនីតិកាលទី៥ ដែលបានប្រសូតចេញពីការបោះឆ្នោតនាថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៣ ដោយលក្ខណៈសេរី យុត្តិធម៌ ត្រឹមត្រូវ និងមានតម្លាភាព ក៏ដូចជាក្នុងនីតិកាលកន្លងមក បានបន្តផ្តោតការយកចិត្តទុកដាក់លើអាទិភាពជាចម្បងក្នុងការបង្កើតការងារកាន់តែប្រសើរជូនប្រជាពលរដ្ឋ ជាពិសេសសម្រាប់យុវជនដែលដល់អាយុចូលធ្វើការប្រមាណ៣សែននាក់ជាមធ្យមក្នុងមួយឆ្នាំ ពីព្រោះការងារគឺជាកត្តាគន្លឹះកំណត់នូវកម្រិតជីវភាព និងជាមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការងារកាត់បន្ថយភាពក្រីក្រ។

ទន្ទឹមនេះ ដើម្បីឈានទៅសម្រេចបាននូវគោលដៅអាទិភាពខាងលើ រាជរដ្ឋាភិបាលកន្លងមកបានខិតខំពង្រឹងនូវបុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍ គឺសន្តិភាព ស្ថិរភាព សន្តិសុខ សណ្តាប់ធ្នាប់សង្គម និងភាពសុខដុមរមនាក្នុងសង្គមជាតិ។ បរិយាកាសអំណោយផលបែបនេះ គឺជាមូលដ្ឋានគ្រឹះអនុញ្ញាតឱ្យប្រជា

ពលរដ្ឋគ្រប់រូប និងគ្រប់និន្នាការ អាចអនុវត្តសិទ្ធិនិងការចូលរួមដោយពេញលេញក្នុងការប្រកបរបរចិញ្ចឹមជីវិត ការបង្កើតសហជីពនិងអង្គការវិជ្ជាជីវៈ ការបញ្ចេញមតិ និងការចូលរួមសកម្មភាពនយោបាយជាដើម។ បរិយាកាសបែបនេះ ក៏បង្កលក្ខណៈឱ្យវិនិយោគិនទាំងក្នុង និងមកពីក្រៅប្រទេសអាចប្រកបសកម្មភាពធុរកិច្ចដោយមានទំនុកចិត្ត និងភាពអាចទាយទុកបានជាមុន ព្រមទាំងដៃគូអភិវឌ្ឍនានា អាចចូលរួមវិភាគទានជាមួយប្រជាពលរដ្ឋកម្ពុជា ក្នុងការនាំយកប្រទេសដ៏អភ័ព្វដែលខ្ទេចខ្ទាំដោយសារសង្គ្រាមរ៉ាំរ៉ៃនេះ ឆ្ពោះទៅកាន់បំណងប្រាថ្នារបស់ខ្លួន គឺវឌ្ឍនភាពនិងវិបុលភាព ដែលងើបចេញផុតពីភាពភ័យខ្លាច ក្រីក្រ និងអត់ឃ្លាន។ កន្លងមក ការរក្សាបាននូវបុរេលក្ខខណ្ឌទាំងនេះ បាននាំឱ្យកម្ពុជាសម្រេចបាននូវកំណើនសេដ្ឋកិច្ចជាមធ្យមខ្ពស់ក្នុងអត្រាពីរខ្ទង់១០% ក្នុងមួយឆ្នាំ នាអំឡុងឆ្នាំ២០០៣-២០០៨ និងប្រមាណ៧% ក្នុងឆ្នាំ២០១០-២០១៣ លើកលែងតែឆ្នាំ២០០៩ ដែលកម្ពុជាទទួលរងឥទ្ធិពលយ៉ាងខ្លាំងពីវិបត្តិកលិយុគហិរញ្ញវត្ថុ និងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក។

ផលលាភពីការរីកលូតលាស់ផ្នែកសេដ្ឋកិច្ចដ៏ឆាប់រហ័សនេះ ត្រូវបានបែងចែកដល់ប្រជាពលរដ្ឋតាមរយៈការកើនឡើងនូវការងារថ្មីៗកាន់តែប្រសើរ ជាពិសេសក្នុងវិស័យក្រៅពីកសិកម្ម។ ជាក់ស្តែងគ្រាន់តែវិស័យវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង ដែលមានរោងចក្រចំនួន៩៦០ បានផ្តល់ការងារដល់កម្មករនិយោជិតចំនួនជិត ៦៣ម៉ឺននាក់។ ក្រៅពីការងារក្នុងស្រុក មានពលករជាង ១០ម៉ឺននាក់ ត្រូវបានបញ្ជូនជាផ្លូវការទៅធ្វើការនៅក្រៅប្រទេស ដែលបាននាំប្រាក់ចំណូលមកក្នុងប្រទេសជាង៣០០លានដុល្លាក្នុងមួយឆ្នាំជាមធ្យម។ កត្តានេះ នាំឱ្យអត្រាគ្មានការងារធ្វើទូទាំងប្រទេសបានថយចុះគួរឱ្យកត់សម្គាល់មកត្រឹមតែ២,៧% ជាពិសេសក្នុងចំណោមយុវជន។ អត្រានៃភាពក្រីក្ររបស់ប្រជាពលរដ្ឋត្រូវបានកាត់បន្ថយយ៉ាងឆាប់រហ័សពី៤៧,៨% ក្នុងឆ្នាំ២០០៧ មកនៅត្រឹម១៩,៨% ក្នុងឆ្នាំ២០១១។

ជាមួយគ្នានេះ ការរីកធំធាត់នៃវិស័យសេដ្ឋកិច្ចរៀបរយ គឺជាមូលដ្ឋានអាចឱ្យរាជរដ្ឋាភិបាលជំរុញលើកកម្ពស់លក្ខខណ្ឌការងារ សុវត្ថិភាពការងារ និងសុខភាពរបស់កម្មករនិយោជិតកាន់តែបានប្រសើរថែមទៀត។ ជាសក្ខីភាពនៃការយកចិត្តទុកដាក់នេះ កម្ពុជាដែលជាប្រទេសសមាជិកអង្គការអន្តរជាតិខាងការងារ(ILO) បានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិការងារចំនួន១៣ ក្នុងនោះរួមទាំងអនុសញ្ញាស្នូលទាំង៨ ដែលជាមូលដ្ឋានឆ្លុះបញ្ចាំងឱ្យមតិអន្តរជាតិបានវាយតម្លៃ និងទទួលស្គាល់ថា កម្ពុជាជាប្រទេសមួយដែលកំពុងបានអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមបទដ្ឋានការងារអន្តរជាតិ។

គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា បានបន្តអនុវត្តពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦។ ការដំឡើងប្រាក់ឈ្នួលអប្បបរមាចំនួន៩ដង ក្នុងរយៈពេល១០ឆ្នាំកន្លងមក ពោលគឺពី៤០ដុល្លាទៅ១០០ដុល្លាក្នុងមួយខែ។ រាជរដ្ឋាភិបាលបានបង្កើតគណៈកម្មការសិក្សាស្រាវជ្រាវប្រាក់ឈ្នួលអប្បបរមា ទន្ទឹមនោះក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បាននិងកំពុងសហការជាមួយអង្គការអន្តរជាតិខាងការងារក្នុងការសិក្សាបង្កើតវិធីសាស្ត្របច្ចេកទេសសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមា ដើម្បីផ្តល់យោបល់ជូនគណៈ-កម្មការប្រឹក្សាការងារ។ លើសពីនេះ ការកើនឡើងនូវឱកាសការងារកាន់តែប្រសើរ និងប្រាក់ឈ្នួលកាន់តែខ្ពស់ បានជំរុញលើកទឹកចិត្តឱ្យមានការចូលរួមក្នុងទីផ្សារការងាររបស់ស្ត្រីកាន់តែច្រើន និងផ្តល់លទ្ធភាពក្នុងការទទួលយកជនពិការ និងជនងាយរងគ្រោះចូលធ្វើការកាន់តែច្រើន។ រីឯកុមារដែល

ចូលរួមក្នុងពលកម្មក្នុងទម្រង់ធ្ងន់ធ្ងរ ត្រូវបានកាត់បន្ថយគួរឱ្យកត់សម្គាល់ ដែលកន្លងមកមានកុមារសរុបចំនួន២០.៥២១នាក់ ត្រូវបានដកហូត និងទប់ស្កាត់។ ការអនុវត្តសិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និងនិយោជកស្របតាមច្បាប់ និងបទប្បញ្ញត្តិការងារ ត្រូវបានធានានិងលើកកម្ពស់ ដោយបច្ចុប្បន្នមានសហជីពបានចុះបញ្ជិកាចំនួន២.៨៩១ ដែលបានកើនឡើង៧១,៤% ធៀបនឹងឆ្នាំ២០០៩។ ទន្ទឹមនេះ យន្តការទំនាក់ទំនងវិជ្ជាជីវៈសំដៅលើកកម្ពស់សុខដុមនីយកម្មក្នុងវិស័យការងារត្រូវបានពង្រឹងតាមរយៈគណៈកម្មាការប្រឹក្សាការងារ ហើយយន្តការដោះស្រាយវិវាទការងារក្រៅប្រព័ន្ធតុលាការ ជាពិសេសការប្រើប្រាស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល ត្រូវបានលើកទឹកចិត្ត និងពង្រីក។ យន្តការគ្រប់គ្រងការបញ្ជូនពលករទៅបរទេស និងការការពារសិទ្ធិនិងផលប្រយោជន៍របស់ពលករខ្មែរនៅបរទេសត្រូវបានធ្វើឱ្យប្រសើរឡើង។

ការរីកចម្រើនក្នុងវិស័យសេដ្ឋកិច្ចនិងការងារ ក៏បានផ្ដល់លទ្ធភាពឱ្យរាជរដ្ឋាភិបាលអាចអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់កម្មករនិយោជិត ដែលបច្ចុប្បន្ននេះ របបធានារ៉ាប់រងហានិភ័យការងារនៃបេឡាជាតិរបបសន្តិសុខសង្គម ត្រូវបានពង្រីកវិសាលភាពគ្របដណ្ដប់ទូទាំង២៤ រាជធានី-ខេត្ត។ របបធានារ៉ាប់រងសុខភាពសម្រាប់កម្មករនិយោជិតនិងគ្រួសារក្នុងបន្ទុក កំពុងត្រូវបានរៀបចំអនុវត្ត ហើយរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករនិយោជិតក្នុងវិស័យឯកជន នឹងអាចចាប់ផ្ដើមដំណើរការនាឆ្នាំ២០១៥ ខាងមុខ។ លើសពីនេះទៀត កន្លងមករាជរដ្ឋាភិបាលក៏បានយកចិត្តទុកដាក់ក្នុងការបញ្ចេញថវិកាជាបន្ទាន់ដើម្បីជួយដោះស្រាយការលំបាករបស់កម្មករនិយោជិតរាប់ពាន់នាក់ ដែលនិយោជកបានបិទទ្វារនិងរត់ចោលរោងចក្រ។ នៅក្នុងដំណាក់កាលដែលវិបត្តិហិរញ្ញវត្ថុនិងការធ្លាក់ចុះនៃសេដ្ឋកិច្ចសកលលោក បានជះឥទ្ធិពលអវិជ្ជមានមកលើជីវភាពរស់នៅរបស់កម្មករនិយោជិត ដោយសាររោងចក្រត្រូវបានផ្អាកដំណើរការនិងបិទទ្វារ រាជរដ្ឋាភិបាលបានបង្កើតមូលនិធិពិសេសសម្រាប់ផ្ដល់សំណាញ់សុវត្ថិភាព និងការបណ្ដុះបណ្ដាលជំនាញដល់កម្មករនិយោជិតដែលបាត់បង់ការងារ និងប្រជាពលរដ្ឋគ្មានការងារធ្វើ រហូតដល់ឆ្នាំ២០១៣។

ក្នុងគោលដៅបន្តលើកកម្ពស់ផលិតភាព សមត្ថភាពប្រកួតប្រជែងប្រាក់ឈ្នួលរបស់កម្មករនិយោជិត និងកម្លាំងពលកម្មកម្ពុជា ព្រមទាំងផ្ដល់ឱកាសលើកទីពីរដល់យុវជនដែលបោះបង់ចោលការសិក្សា រាជរដ្ឋាភិបាលបានផ្ដល់ធនធានកាន់តែច្រើនថែមទៀតដើម្បីសាងសង់មជ្ឈមណ្ឌលបណ្ដុះបណ្ដាលវិជ្ជាជីវៈនៅគ្រប់រាជធានី-ខេត្ត ដែលគិតពីឆ្នាំ២០០៩ ដល់២០១៣ បានផ្ដល់ការបណ្ដុះបណ្ដាលដល់សិក្ខាកាមសិស្ស និស្សិតសរុបចំនួន ៦៣៣ ៤៥៩នាក់។ ទន្ទឹមនេះ ការផ្ដល់សេវាសាធារណៈរបស់រដ្ឋក្នុងវិស័យការងារឆ្លើយតបកាន់តែប្រសើរទៅនឹងសេចក្ដីត្រូវការរបស់ប្រជាពលរដ្ឋ ត្រូវបានពង្រីកដូចជាការបង្កើតទីភ្នាក់ងារជាតិមុខរបរ និងការងារ ដើម្បីផ្ដល់សេវាក្នុងការជួយស្វែងរកការងារ ផ្ដល់ព័ត៌មានពីឱកាសការងារកាន់តែទូលំទូលាយ និងងាយស្រួលជូនប្រជាពលរដ្ឋដល់ទីជនបទ ព្រមទាំងផ្ដល់ការគាំទ្រដល់និយោជកក្នុងការជ្រើសរើសកម្លាំងពលកម្មបានឆាប់រហ័ស។

*បងប្អូនកម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់!*

ទោះបីជាសម្រេចបាននូវជោគជ័យក្នុងវិស័យការងារគួរជាទីមោទនៈ ដូចបានលើកឡើងខាងលើ ក៏កម្ពុជានៅមានបញ្ហាប្រឈមថ្មីៗក្នុងការថែរក្សាការពារការងារដែលមានស្រាប់ និងបង្កើតការងារថ្មីកាន់តែ

ប្រសើរសម្រាប់កម្លាំងពលកម្មដែលមានវ័យក្មេង ព្រមទាំងការបណ្តុះបណ្តាលលើកកម្ពស់ជំនាញពលករកម្ពុជាប្រកបដោយសមត្ថភាព និងគុណភាព ដើម្បីគាំទ្រដល់ពិពិធភាវូបនីយកម្មមូលដ្ឋានផលិតកម្ម, លើកកម្ពស់ផលិតភាព និងសមត្ថភាពប្រកួតប្រជែង ទាក់ទាញវិនិយោគ ស្រូបយកបច្ចេកវិទ្យាថ្មីនិងទាញយកប្រយោជន៍អតិបរិមាពីសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥។

វិបត្តិហិរញ្ញវត្ថុ និងសេដ្ឋកិច្ចសកលលោកកន្លងមក បានបង្ហាញឱ្យឃើញថា សេដ្ឋកិច្ចកម្ពុជានៅមានភាពងាយរងគ្រោះពីវិបត្តិខាងក្រៅ ដែលអាចនាំឱ្យមានការបាត់បង់ការងារ និងខ្វះលទ្ធភាពក្នុងការបង្កើតការងារថ្មីគ្រប់គ្រាន់សម្រាប់យុវជន ហើយឈានទៅកើតមានវិបត្តិវិស័យការងារនៅក្នុងប្រទេស។ លើសពីនេះ បាតុកម្មនិងកុបកម្មហឹង្សាក្នុងពេលថ្មីៗបំផុតនេះ ជាពិសេសបង្កឡើងដោយក្រុមជនអនាធិបតេយ្យដោយមានការញុះញង់ពីជនខិលខូច និងអ្នកនយោបាយឱកាសនិយម គឺជាសញ្ញាព្រមានជាថ្មីឱ្យឃើញថា ភាពវឹកវរក្នុងទីផ្សារការងារអាចបណ្តាលឱ្យបាត់បង់សណ្តាប់ធ្នាប់ ស្ថិរភាពសង្គម ព្រមទាំងជំនឿទុកចិត្តពីវិនិយោគិន និងអាចឈានទៅបង្កើតឱ្យមានឡើងនូវបញ្ហាសង្គមធ្ងន់ធ្ងរសារជាថ្មីដែលកម្ពុជាធ្លាប់បានឆ្លងកាត់យ៉ាងឈឺចាប់ក្នុងអតីតកាល។ បញ្ហានេះ នឹងបំផ្លាញលក្ខខណ្ឌចាំបាច់ នឹងធ្វើឱ្យរាំងស្ទះដល់ដំណើរការឧស្សាហូបនីយកម្ម ការអភិវឌ្ឍសេដ្ឋកិច្ចជាតិ និងការខិតខំក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ព្រមទាំងគំរាមដល់ការទាញយកប្រយោជន៍ពីសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ដ៏ខ្លីខាងមុខ ដំណើរការឈានទៅសម្រេចមហិច្ឆតាក្នុងការប្រែក្លាយខ្លួនទៅជាប្រទេសដែលមានចំណូលមធ្យម និងឱកាសក្នុងការរក្សាតួនាទីកម្ពុជាជាប្រទេសស្មើសិទ្ធិស្មើភាពក្នុងសហគមន៍អន្តរជាតិ។

ប្រឈមនឹងស្ថានភាពដ៏គ្រោះថ្នាក់នេះ រាជរដ្ឋាភិបាលបានប្រកាន់យកវិធានការស្របច្បាប់ ទន់ភ្លន់ និងអត់ធ្មត់អតិបរិមា សំដៅស្តារនិងរក្សាសណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈ ដើម្បីការពារជីវិតនិងទ្រព្យសម្បត្តិប្រជាពលរដ្ឋនិងសាធារណៈ ព្រមទាំងធ្វើឱ្យប្រសើរឡើងវិញនូវបរិយាកាសសង្គម ធុរកិច្ច និងការទុកចិត្តពីវិនិយោគិន ដែលជាមូលដ្ឋានមិនអាចខ្វះបានក្នុងការឈានទៅធានាកំណើនសេដ្ឋកិច្ច បង្កើតការងារជូនប្រជាពលរដ្ឋ ព្រមទាំងដំណើរប្រជាធិបតេយ្យនីយកម្ម និងការលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា។

ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមកោតសរសើរយ៉ាងស្មោះស្ម័គ្រចំពោះការខិតខំប្រឹងប្រែងរបស់ក្រសួងស្ថាប័នពាក់ព័ន្ធនានា ជាពិសេសក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ គណៈកម្មការប្រឹក្សាការងារ គណៈកម្មការសម្រាប់ដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា ដែលកន្លងមកនេះ បានរួមចំណែកយ៉ាងសកម្មក្នុងការបង្ការទប់ស្កាត់ និងដោះស្រាយវិវាទការងារដោយសន្តិវិធី ដើម្បីបង្កើតឡើងនូវភាពយោគយល់គ្នាក្នុងទំនាក់ទំនងវិជ្ជាជីវៈរវាងភាគីពាក់ព័ន្ធទាំងអស់។ លទ្ធផលវិជ្ជមានទាំងនេះ សុទ្ធតែមានការចូលរួមយ៉ាងសកម្ម និងសុឆន្ទៈពីសំណាក់អង្គការវិជ្ជាជីវៈរបស់កម្មករនិយោជិត និងនិយោជក ក៏ដូចជាអង្គការអន្តរជាតិជាដៃគូ ផងដែរ។

*បងប្អូនកម្មករនិយោជិត និយោជក និងជនរួមជាតិទាំងអស់ជាទីស្នេហា !*

ដើម្បីជំនះ នូវបញ្ហាប្រឈមខាងលើ សំដៅលើកកម្ពស់លក្ខខណ្ឌការងារ គុណភាព ស្ថិរភាព និងរបបសន្តិសុខសង្គម ផលិតភាព ភាពប្រកួតប្រជែង ភាពសុខដុមមនាទំនាក់ទំនងវិជ្ជាជីវៈ និងកម្រិតជីវភាព

កម្មករនិយោជិត ព្រមទាំងអភិវឌ្ឍវិស័យការងារកម្ពុជាឈានទៅកាន់របត់សង្គម-សេដ្ឋកិច្ចថ្មី និងការចូលរួមក្នុងសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ ខ្ញុំសូមឆ្លៀតក្នុងឱកាសនេះ ធ្វើការអំពាវនាវចំពោះក្រសួង ស្ថាប័ន រាជរដ្ឋាភិបាលគ្រប់លំដាប់ថ្នាក់ ក៏ដូចជានិយោជក កម្មករនិយោជិត សមាគមនិយោជក អង្គការសហជីព ព្រមទាំងអង្គការមិនមែនរដ្ឋាភិបាល និងអង្គការអន្តរជាតិពាក់ព័ន្ធទាំងអស់ សូមយកចិត្តដាក់លើប្រការដូចខាងក្រោមនេះ៖

១-បន្តខិតខំលើកកម្ពស់លក្ខខណ្ឌការងារឱ្យកាន់តែប្រសើរឡើង តាមរយៈការបន្តអនុវត្តនូវគោលនយោបាយផ្សារភ្ជាប់ពាណិជ្ជកម្មទៅនឹងលក្ខខណ្ឌការងារ ពង្រឹងការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់ស្តីពីរបបសន្តិសុខសង្គម ច្បាប់ស្តីពីកិច្ចការពារ និងលើកកម្ពស់សិទ្ធិជនពិការ បទប្បញ្ញត្តិពាក់ព័ន្ធ និងអនុសញ្ញាអន្តរជាតិនានា។ រៀបចំ និងអនុវត្តយន្តការអធិការកិច្ចការងារតែមួយ ក្នុងពេលតែមួយ និងប្រើបទដ្ឋានវាយតម្លៃតែមួយ សំដៅពង្រឹងគុណភាព តម្លាភាព ប្រសិទ្ធភាពនៃការធ្វើអធិការកិច្ចការងារ និងកាត់បន្ថយបន្ទុកលើនិយោជក ពង្រឹងភាពសុខដុមរមនានៃទំនាក់ទំនងវិជ្ជាជីវៈ លើកកម្ពស់ការយល់ដឹងអំពីសិទ្ធិនិងកាតព្វកិច្ចស្របច្បាប់របស់កម្មករនិយោជិត និងនិយោជក បង្កើនប្រសិទ្ធភាពវិធានការណ៍ការពារ ទប់ស្កាត់ និងដោះស្រាយវិវាទដោយសន្តិវិធី ដោយសិក្សារកមូលហេតុពិតប្រាកដឱ្យបានឆាប់រហ័ស និងយកចិត្តទុកដាក់ដោះស្រាយតាំងពីចាប់ផ្តើមរហូតដល់ចប់ អនុវត្តទៅតាមនីតិវិធីច្បាប់ជាធរមាន ជាពិសេសចៀសវៀងឱ្យបានដាច់ខាតនូវការរំខានដល់សណ្តាប់ធ្នាប់សាធារណៈ និងការប្រើអំពើហឹង្សា ដែលបណ្តាលឱ្យបាត់បង់ផលប្រយោជន៍ដល់គ្រប់ភាគីពាក់ព័ន្ធ រួមទាំងសង្គមជាតិផង។

២-ត្រូវបន្តពង្រឹងឱ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធការពារសុខភាព និងសុវត្ថិភាពការងារ ជាពិសេសយកចិត្តទុកដាក់លើបរិស្ថាន អនាម័យ អាហារូបត្ថម្ភ និងសេវាការពារសុខភាពនៅកន្លែងការងារ និងសេវាពិនិត្យសុខភាពទប់ស្កាត់ជម្ងឺឆ្លងនានា លើកកម្ពស់សុវត្ថិភាពអគ្គីភ័យនិងសំណង់ ព្រមទាំងរួមគ្នាទប់ស្កាត់កុំឱ្យមានគ្រោះថ្នាក់ការងារ និងគ្រោះថ្នាក់ក្នុងការដឹកជញ្ជូនកម្មករនិយោជិត ដោយអនុវត្តនូវទិសស្លោក "ថ្ងៃនេះ ថ្ងៃស្អែក កុំឱ្យមានគ្រោះថ្នាក់ចរាចរ" ជំរុញយុទ្ធនាការគ្រោះថ្នាក់ការងារកំរិតសូន្យ។

៣-បន្តពង្រឹង និងពង្រីកសេរីភាពសហជីពនិងអង្គការវិជ្ជាជីវៈ ទប់ស្កាត់ការរើសអើងចំពោះសហជីព និងលើកកម្ពស់ភាពជាតំណាងបំផុតដោយពន្លឿនការអនុម័តច្បាប់ស្តីពីសហជីព ព្រមទាំងពង្រឹងប្រសិទ្ធភាព និងតម្លាភាពនៃនីតិវិធីចុះបញ្ជិកាអង្គការវិជ្ជាជីវៈ។

៤-ប្រឹងប្រែងសិក្សាឱ្យបានម៉ត់ចត់ និងគ្រប់ជ្រុងជ្រោយទាំងទិដ្ឋភាពសង្គម សេដ្ឋកិច្ច និងគតិយុត្តិក្នុងការបង្កើតវិធីសាស្ត្របច្ចេកទេសសម្រាប់កំណត់ប្រាក់ឈ្នួលអប្បបរមានៃគណៈកម្មការសិក្សាស្រាវជ្រាវកំណត់ប្រាក់ឈ្នួលអប្បបរមាក្នុងវិស័យវាយនភ័ណ្ឌ កាត់ដេរ និងផលិតស្បែកជើង និងគណៈកម្មការប្រឹក្សាការងារ ដោយជំរុញឱ្យមានការចូលរួមពិគ្រោះយោបល់ទូលំទូលាយពីគ្រប់ភាគីពាក់ព័ន្ធ និងអង្គការអន្តរជាតិដែលមានជំនាញ សំដៅបង្កើតតម្លាភាព ភាពទុកចិត្តពីគ្រប់ភាគី ស្ថិរភាព និងកាត់បន្ថយវិវាទក្នុងឧស្សាហកម្ម កាត់ដេរកម្ពុជា។ លើសពីនេះ ត្រូវយកចិត្តទុកដាក់ខិតខំជំរុញការចរចាជាសមូហភាព និងការធ្វើអនុសញ្ញារួម ដើម្បីពង្រឹងភាពសុខដុមរមនា រវាងកម្មករនិយោជិត និងនិយោជក។

៥- កម្មករនិយោជិត យុវជន និងមាតាបិតា គួរឆ្លៀតឱកាស និងងាកមកបញ្ជូនកូនចៅទៅទទួលការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដើម្បីលើកកម្ពស់ជំនាញ ផលិតភាពការងារ សមត្ថភាពប្រកួតប្រជែង និងអាចឈានចូលទៅក្នុងទីផ្សារការងារបានឆាប់រហ័ស និងងាយស្រួល ព្រមទាំងដើម្បីត្រៀមលក្ខណៈទាញយកប្រយោជន៍ឱ្យបានជាអតិបរិមាពីសហគមន៍សេដ្ឋកិច្ចអាស៊ាននាឆ្នាំ២០១៥ ដ៏ខ្លីខាងមុខ។ ទន្ទឹមនឹងនេះ និយោជកគ្រប់ប្រភេទត្រូវបង្កភាពងាយស្រួល និងផ្តល់ការលើកទឹកចិត្តដល់កម្មករនិយោជិត ក្នុងការចូលរួមធ្វើការបណ្តុះបណ្តាលលើកកម្ពស់ជំនាញគ្រប់ប្រភេទ។

៦-ប្រជាពលរដ្ឋដែលមានបំណងស្វែងរកការងារធ្វើ សូមប្រើប្រាស់សេវារកការងារធ្វើរបស់រដ្ឋតាមរយៈទីភ្នាក់ជាតិមុខរបរ និងការងារ ដើម្បីទទួលបានព័ត៌មានអំពីឱកាសការងារគ្រប់ប្រភេទ និងទទួលបានការងារធ្វើឆាប់រហ័ស និងចំណាយតិច ចៀសវាងការធ្វើចំណាកស្រុកដោយខុសច្បាប់ទាំងប្រថុយប្រថានទៅរកការងារធ្វើនៅក្រៅប្រទេស។ ទន្ទឹមនេះ មន្ត្រីជំនាញពាក់ព័ន្ធទាំងអស់ត្រូវចាត់វិធានការម៉ឺងម៉ាត់ចំពោះជនជាមេខ្យល់ដែលប្រើឧបាយកលអូសទាញ ឬបោកបញ្ឆោតប្រជាពលរដ្ឋឱ្យធ្វើចំណាកស្រុក ដើម្បីទៅធ្វើការនៅបរទេសដោយខុសច្បាប់។

៧- សូមយកឱកាសទិវាពលកម្មអន្តរជាតិថ្ងៃទី១ ខែឧសភា នេះ ធ្វើការរៀបចំសកម្មភាពវប្បធម៌ សិល្បៈ ការលំហែ ការកំសាន្តរីករាយតាមលទ្ធភាព និងលក្ខណៈសម្បត្តិរៀងៗខ្លួន ហើយចៀសវាងឱ្យបានដាច់ខាតនូវការជឿតាមការញុះញង់របស់ជនខិលខូចឱ្យធ្វើសកម្មភាពខុសច្បាប់នានា ដែលនាំឱ្យប៉ះពាល់ដល់ផលប្រយោជន៍របស់បងប្អូនកម្មករនិយោជិត ឱ្យរំខានដល់សណ្តាប់ធ្នាប់សាធារណៈ និងបរិយាកាសសប្បាយរីករាយរបស់សង្គមជាតិ។

ជាទីបញ្ចប់ ខ្ញុំសូមឆ្លៀតឱកាសដ៏ថ្លៃថ្លានេះ ប្រសិទ្ធិពរជូនដល់បងប្អូនកម្មករនិយោជិត ជនរួមជាតិដែលកំពុងធ្វើការក្នុង និងក្រៅប្រទេស ក៏ដូចជាអស់លោក លោកស្រី ជានិយោជក និងនិយោជិតបរទេស ជាមន្ត្រីអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ ដែលកំពុងស្នាក់នៅ និងបំពេញភារកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា សូមទទួលបាននូវជោគជ័យ និងវិបុលសុខគ្រប់ប្រការ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែមេសា ឆ្នាំ ២០១៤

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**